រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# ការអនុវត្តន៍ល្អ

## ការរៀបចំប៉ុស្តិ៍ការងារនៅផ្នែកអ៊ុត

ការរៀបចំប៉ុស្តិ៍ការងារនៅផ្នែកអ៊ុតល្អ មានសារៈសំខាន់ចំពោះផលិតភាព និងប្រសិទ្ធភាពការងារ ។ គ្រាន់តែផ្លាស់ប្តូរបន្តិចបន្តួចក្នុងការរៀបចំប៉ុស្តិ៍ការងារ អាចធ្វើអោយមានការប្រែប្រួលយ៉ាងធំធេងដល់ផលិតភាព សុខភាព និងសុវត្ថិភាពការងារ ។

### ការអនុវត្តន៍ល្អសំរាប់ការរៀបចំប៉ុស្តិ៍ការងារនៅផ្នែកអ៊ុត

តខ្សែឆ្នាំងអ៊ុតយឺត (អេឡាសស្ទិច) ជាមួយនឹងឆ្នាំងអ៊ុត ដើម្បីកាត់បន្ថយភាពនឿយហត់របស់កម្មករ និងបង្កើនផលិតភាព (រូបភាពទី១) ។

ផ្តល់ទ្រនាប់ឆ្នាំងអ៊ុត ដែលអាចដាក់ឆ្នាំងអ៊ុតលើបាន នៅពេលមិនត្រូវការប្រើប្រាស់វា ។ ធ្វើដូចនេះ អាចការពារដល់ផ្ទៃបាតឆ្នាំងអ៊ុត និងរក្សាភាពស្អាត (រូបភាពទី២) ។

ផ្តល់ទ្រនាប់ទន់ទ្រជើងដល់កម្មករសំរាប់ឈរលើ ដើម្បីកាត់បន្ថយភាពនឿយហត់ និងបង្កើនផលិតភាព (រូបភាពទី៣) ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្កើនផលិតភាព
- ✓ ធ្វើអោយគុណភាពផលិតផលមានភាពប្រសើរឡើង
- ✓ កាត់បន្ថយចំនួនអវត្តមានរបស់កម្មករដោយសារជំងឺ
- ✓ បង្ហាញអោយឃើញពីការយកចិត្តទុកដាក់របស់រោងចក្រទាក់ទងនឹងសុខភាព និងសុខមាលភាពកម្មករ

### តាមរបៀបណា:

- ✓ រៀបចំអោយមានខ្សែឆ្នាំងអ៊ុតយឺត ទម្រជើងសំរាប់កម្មករ និងទម្រឆ្នាំងអ៊ុតដល់ប៉ុស្តិ៍ការងារអ៊ុតនីមួយៗ
- ✓ គ្រប់សំភារៈអាចរកទិញបាននៅក្នុងប្រទេសកម្ពុជា

### តំលៃ:

**$** ____________

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់

អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org